ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៣៧/០៩ និង ១៣៨/០៩-ញូ ភាញ់

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: ពីរ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ញូ ភាញ់ ធីឈក្រេត (ខេមបូឌា) ម៉ិកាត់

អាសយដ្ឋាន : ផ្លូវជាតិលេខ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៥១ ៥០៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ចៅ ផេង នាយករងក្រុមហ៊ុន

២- លោក ឈឿង វណ្ណៈ ទីប្រឹក្សាក្រុមហ៊ុន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហជីពសេរីកម្មករ នៃក្រុមហ៊ុន ញូ ភាញ់

អាសយដ្ឋាន : ផ្លូវជាតិលេខ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨៨២ ២៨៤ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោករ៉ូ សុផាត មន្ត្រីដោះស្រាយវិវាទ FTUWKC

២- កញ្ញា រ៉ូ សុភ័ណ្ឌ ប្រធានសហជីពសេរីកម្មករនៃក្រុមហ៊ុន ញូ ភាញ់



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

| | |
|---|---|
| ៣- កញ្ញា ម៉ាត់ សុនហេង | អនុប្រធានសហជីព |
| ៤- កញ្ញា ស្លាត សុភាព | លេខាធិការសហជីព |
| ៥- កញ្ញា សុខ ដានី | សមាជិក |
| ៦- កញ្ញា ជុំ ចន្ទ្រា | សមាជិក |
| ៧- កញ្ញា ឃុត ស្រីផុន | សមាជិក |
| ៨- កញ្ញា ណេក រ៉ាត់ | សមាជិក |
| ៩- កញ្ញា ណេកស សាមី | សមាជិក |
| ១០- លោក ហ៊ុន សំណាង | សមាជិក |
| ១១- កញ្ញា ពេជ្រ គន់ធឿន | សមាជិក |
| ១២- កញ្ញា ហ៊ិន ស្រីទូច | សមាជិក |
| ១៣- កញ្ញា ប៉ែប ផល្លី | សមាជិក |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ក/. ចំណុចវិវាទនៃសំណុំរឿងលេខ ១៣៧/០៩ :

១- នាយករោងចក្រមិនត្រូវរើសអើងសហជីពឡើយ ។

២- រោងចក្រត្រូវជួយកាត់ភាគទានជូនសហជីពតាមសំណើរបស់កម្មករ ។

៣- នៅពេលរោងចក្រគ្មានការងារឱ្យកម្មករធ្វើ ហើយឱ្យសម្រាកផ្តល់ប្រាក់ឈ្នួល ៥០ ភាគរយ ក្រុមហ៊ុនត្រូវផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ជូន ។

៤- នៅពេលកម្មការិនីទៅពិនិត្យផ្ទៃពោះ ត្រូវអនុញ្ញាតឱ្យឈប់សម្រាកពេញមួយថ្ងៃក្នុងមួយខែ ។

៥- នៅពេលកម្មករបានចុះទាំកាត់ ហើយចេញមុនកន្លះម៉ោង មិនត្រូវកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ឡើយ ។

៦- ពេលរោងចក្រចង់ប្តូរកម្មករទៅធ្វើការនៅផ្នែកផ្សេង ត្រូវមានការយល់ព្រមពីកម្មករជាមុនសិន ។

៧- សូមឱ្យលោក ចៅ ផេង ប្រើរភាកប្បកិរិយា និងពាក្យសំដីឱ្យបានសមរម្យ ។

៨- រោងចក្រត្រូវបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតឱ្យចប់ត្រឹមម៉ោង ១៦:០០ ។

៩- នៅពេលកម្មករបានចុះទាំកាត់ ហើយមិនអាចយកសុំច្បាប់ផ្ទាល់បាន អាចផ្ញើកាតផ្តាំតាមប្រធានក្រុម ឬ អ្នកស្គាល់គ្នា ។

១០- រោងចក្រមិនត្រូវធ្វើការព្រមានកម្មករនិយោជិតដែលគ្រាន់តែទៅបន្ទប់ទឹកលើសពេល ៥ នាទី ។

ខ/. ចំណុចវិវាទនៃសំណុំរឿងលេខ ១៣៨/០៥ :

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ៥០ ភាគរយ ក្នុងមួយខែ នៅពេលក្រុមហ៊ុនព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៥ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ និងមិនទទួលស្គាល់ការព្រមព្រៀងរវាងក្រុមហ៊ុន និងប្រតិភូបុគ្គលិកដែលយល់ព្រមទទួលយកប្រាក់ឈ្នួលចំនួន ១៣ ដុល្លារក្នុងមួយខែជំនួសការស្នាក់នៅ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារខាងលើបានឡើយ ដោយរង់ចាំសេចក្តីសម្រេចពីនាយកដ្ឋានអធិការកិច្ចការងារ ។

២- ករណីពេលត្រលប់ចូលធ្វើការវិញ ក្រុមហ៊ុននៅតែគ្មានការងារឱ្យកម្មករនិយោជិតធ្វើទៀត សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ឬបញ្ចប់កិច្ចសន្យាការងារទៅតាមច្បាប់ស្តីពីការងារ ។ ដោយឡែក ភាគីក្រុមហ៊ុនពុំអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៩១៥ ក.ប/អក/វ.ក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៥ (សំណុំរឿងលេខ ១៣៧/០៥) និង លេខ ៩២៤ ក.ប/អក/វក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ (សំណុំរឿងលេខ ១៣៨/០៥) ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ ។

### សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលបរិច្ឆេទជួបជុំមុនសវនាការ :

- លើកទី១ : ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៥ (វេលាម៉ោង ១០:៣០ នាទី ព្រឹក) ។
- លើកទី២ : ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥ (វេលាម៉ោង ១៦:០០ នាទី ល្ងាច) ។

បញ្ហានៃនីតិវិធី ៖

ក្រុមហ៊ុន ញូ ភាញ់ វីលគ្រេត កម្ពុជា ចំកាត់ មានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានទាមទារឱ្យក្រុមហ៊ុនកែលំអរនូវលក្ខខណ្ឌការងារមួយចំនួន ឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ១០ ចំណុច ដែលសហជីពនេះបានធ្វើការទាមទារ ប៉ុន្តែ ពុំមានចំណុចណាមួយបានទទួលលទ្ធផលសះជានឹងគ្នាទេ (*នៅក្នុងរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩១៩ ក.ប/កណ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ នៃសំណុំរឿងលេខ ១៣៧/០៩*) ហើយក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនប្រហែល ៥០១ នាក់។

ទន្ទឹមនឹងនេះដែរ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងតាមទូរសព្ទរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០២ ចំណុច បន្ថែមទៀត។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ០២ ចំណុច ប៉ុន្តែ ពុំមានចំណុចណាមួយបានទទួលលទ្ធផលសះជានឹងគ្នាទេ (*នៅក្នុងរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩២៤ ក.ប/កណ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ នៃសំណុំរឿងលេខ ១៣៨/០៩*) ហើយក្រុមហ៊ុនមានកម្មករនិយោជិតចំនួនប្រហែល ៥០១ នាក់។

ចំណុចមិនសះជាដែលមាននៅក្នុងរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩១៩ ក.ប/កណ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ (សំណុំរឿងលេខ ១៣៧/០៩) និងនៅក្នុងរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩២៤ ក.ប/កណ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ (សំណុំរឿងលេខ ១៣៨/០៩) បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩។ សូមបញ្ជាក់ដែរថា នៅក្នុងសំណុំរឿងនេះ គូភាគីនៃវិវាទ គឺតំណាងនិយោជកនៃក្រុមហ៊ុន ញូ ភាញ់ និងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកិច្ចព្រមព្រៀងមួយស្តីពីការដាក់បញ្ចូលសំណុំរឿងលេខ ១៣៧/០៩ និង ១៣៨/០៩ ជាសំណុំរឿងតែមួយ សម្រាប់ឱ្យក្រុមអាជ្ញាកណ្តាលដែលធ្វើការដោះស្រាយ។

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ដដែល លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទទួលលិខិតបន្ថែមពីភាគីនិយោជក ចុះនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ដែលបញ្ជាក់ថា មានកម្មករ កម្មការិនីរបស់ក្រុមហ៊ុនដែលមានចំនួនប្រហែល ៣០០ នាក់ បានធ្វើកូដកម្ម តាំងពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩ ហើយភាគីក្រុមហ៊ុនបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា បញ្ឈប់កូដកម្មរបស់កម្មករនិយោជិត ព្រោះកូដកម្មនេះបានធ្វើឱ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន។ បន្ទាប់មក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

បានអញ្ជើញភាគីទាំងពីរមកជ្រើសរើសអាជ្ញាកណ្តាលក្នុងបញ្ជីរៀង១ខ្លួន ដើម្បីបង្កើតជាក្រុមអាជ្ញាកណ្តាល ដោះស្រាយបញ្ហាវិវាទនៅក្នុងសំណុំរឿងទាំងពីរនេះ (*សំណុំរឿងលេខ ១៣៧/០៩ និង សំណុំរឿងលេខ ១៣៨/០៩*) ។ ភាគីទាំងពីរបានមកជ្រើសរើសអាជ្ញាកណ្តាលដោយផ្ទាល់ ហើយក្រុមអាជ្ញាកណ្តាលបានបង្កើតឡើង ។ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យភាគីចូលរួម ដើម្បីសាកសួររកព័ត៌មានបន្ថែម ហើយក៏បានចេញសេចក្តីបញ្ជាឱ្យភាគីកម្មករនិយោជិតបញ្ឈប់ធ្វើកូដកម្ម ដោយតម្រូវឱ្យកម្មករនិយោជិតចូលធ្វើការវិញនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ ដើម្បីរង់ចាំក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោះស្រាយលើអង្គសេចក្តីនៃវិវាទការងាររួមនេះ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានត្រឡប់ចូលទៅធ្វើការតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ គឺនៅតែបន្តធ្វើកូដកម្មដដែល ។ បន្ទាប់ពីទទួលដំណឹងអំពីការបន្តធ្វើកូដកម្មរបស់កម្មករនិយោជិតមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជក មកជួបប្រជុំមុនសវនាការនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ជាលើកទី២ ហើយភាគីនិយោជក និងភាគីកម្មករនិយោជិតមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ នៅក្នុងការជួបប្រជុំមុនសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរភាគីអំពីបញ្ហាពាក់ព័ន្ធការធ្វើកូដកម្មរបស់ភាគីកម្មករនិយោជិត និងការអនុញ្ញាតរបស់ភាគីនិយោជក ឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង១ខ្លួន ។ ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតមិនចូលធ្វើការទេ គឺនៅតែបន្តធ្វើកូដកម្ម បើភាគីនិយោជកមិនព្រមដោះស្រាយនូវសោហ៊ុយដែលនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ០២ ខែ ដែលគិតចាប់តាំងពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នោះទេ ។ កម្មករនិយោជិតបានបញ្ជាក់ពីការទាមទាររបស់ខ្លួនចុងក្រោយចំនួន ១៦ ដុល្លារអាមេរិក ប៉ុន្តែ ភាគីក្រុមហ៊ុនបញ្ជាក់ថា មិនអាចមានលទ្ធភាពផ្តល់ជូនតាមការទាមទារបានទេ គឺក្រុមហ៊ុនមានលទ្ធភាពផ្តល់ជូនត្រឹមតែ ១៣.៥០ ដុល្លារអាមេរិក ដោយយោងទៅតាមលទ្ធភាពរបស់ក្រុមហ៊ុន និងស្ថានភាពដែល រកមានទំនិញដេរ ដែលក្រុមហ៊ុនកំពុងជួបប្រទះនាពេលសព្វថ្ងៃ ។ ប៉ុន្តែ ភាគីក្រុមហ៊ុននៅតែបើកទ្វារអនុញ្ញាតឱ្យ កម្មករនិយោជិតដែលមិនទាន់បានបញ្ចប់ការងាររបស់ខ្លួនចូលធ្វើការ ប៉ុន្តែ កម្មករនិយោជិតមិនព្រមចូលធ្វើការទេ ។

ក្រោយពីស្តាប់ភាគីទាំងពីររួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង១ខ្លួន ហើយស្នើឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀង១ខ្លួនដែរ ដើម្បីទុកលទ្ធភាពឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តនីតិវិធីដោះស្រាយវិវាទទាំងនេះ តាមច្បាប់ស្តីពីការងារ ប៉ុន្តែ រហូតមកដល់នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នេះ កម្មករនិយោជិតនៅតែបន្តកូដកម្មដដែល ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា ដូចខាងក្រោម :

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញ៉ូ ភាញ់ លេខ ៩១៩ ក.ប/អក/វ.ក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ញ៉ូ ភាញ់ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩។

៣- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញ៉ូ ភាញ់ លេខ ៩២៤ ក.ប/អក/វ.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ញ៉ូ ភាញ់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៧១៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៧១៧ កប/អក/វក/លកអ. ចុះថ្ងៃទី ០៧ ខែយុលា ឆ្នាំ២០០៩។

## អង្គហេតុ:

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជាដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន។

## ហេតុផលនៃសេចក្តីសម្រេច

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា "*ក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្តល់ការបរិយាយ*

*ការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្ដីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម ។"*

បន្ថែមលើនេះទៀត នៅក្នុងសេចក្ដីបញ្ជាមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើការឡុកអៅ ។

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងសំណុំរឿងមុនៗ ដូចខាងក្រោម:

នៅក្នុងសេចក្ដីសម្រេចអាជ្ញាកណ្ដាលលេខ ០៤/០៤-រីម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្ដីជូនដំណឹងនេះ ចែងថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្ដីសម្រេចលើវិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចដោះស្រាយវិវាទការងាររួមនេះម្ដងទៀត បាននៅពេលណាដែលសហជីព កម្មករនិយោជិតទាំងអស់ ឈប់ធ្វើកូដកម្ម ។"*

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រូអ៊ិក្ស នីតធីង ប្លាមេន ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា *" នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។"*

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី រីម និង សំណុំរឿងលេខ ៣៨/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក៏បានចេញសេចក្ដីសម្រេចបិទសំណុំរឿងទាំងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល *(សូមមើលបន្ថែមក្នុងសេចក្ដីសម្រេចអាជ្ញាកណ្ដាលលេខ ៩៧/០៧-ស៊ូត វ៉ើ, លេខ ៦៣/០៨-សៅធន៍ ហ៊ើរ និង ហ្គោលឌិន ហ្វ្លាន) ។*

ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងលេខ ១៣៧/០៩ និង លេខ ១៣៨/០៩ ) របស់ក្រុមហ៊ុន ញូ ភាញ់ វីយេត្រេត កម្ពុជា ធីកាត់ នេះ ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ពួកគេមានបំណងយកវិវាទការងាររួមនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ព្រោះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ហើយមិនគោរពតាមបញ្ជា និងការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

ហេតុដូច្នេះ ដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ :

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៣៧/០៩ និង លេខ ១៣៨/០៩-ញ៉ូ ភាញ់ វីល ព្រេត កម្ពុជា ចំកាត់ នេះទេ ។

### ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : អ៊ឹង សុទ្ធី

ហត្ថលេខា: -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : ឈឹម សុវណ្ណារ៉ា

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : គង់ ផល្លះ

ហត្ថលេខា: -----------------------------